ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១៦១៦ ការស៊ល

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៤

# ជម្រាបមក
# ឯកឧត្តមអភិបាលខេត្តបាត់ដំបង សៀមរាប កំពត និងខេត្តកំពង់ចាម

**កម្មវត្ថុ** : ស្តីពីការពង្រឹងការផ្សព្វផ្សាយព័ត៌មានឱ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋ តាមរយៈការចូលរួមអនុវត្តគម្រោង ជំនួយផ្នែកទំនាក់ទំនងនៅកម្ពុជា(Cambodia communication Assistance Project "CCAP" )។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ក្រសួងមហាផ្ទៃសូមជម្រាបមកឯកឧត្តមអភិបាលជ្រាបថា ដោយពិនិត្យឃើញពីសារៈសំខាន់នៃការផ្តល់ និងទទួលព័ត៌មានពីប្រជាពលរដ្ឋ ដែលជាផ្នែកមួយនៃការពង្រឹងគណនេយ្យភាពសង្គម ក្រសួងបានចាត់មន្ត្រីឱ្យចូលរួមជាសមាជិកក្រុមការងារពិគ្រោះយោបល់ ដើម្បីជំរុញការអនុវត្តគម្រោងជំនួយផ្នែកទំនាក់ទំនងនៅកម្ពុជា។ គម្រោងនេះបានទទួលហិរញ្ញប្បទានពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់អូស្ត្រាលី ផ្តល់ជូនក្រសួងព័ត៌មាន សហការជាមួយវិទ្យុអេប៊ីស៊ីអូស្ត្រាលី សំដៅពង្រឹងការងាររបស់មន្ទីរព័ត៌មាននៅខេត្តបាត់ដំបង កំពត កំពង់ចាម និងខេត្តសៀមរាបតាមរយៈការបង្កើតកម្មវិធី Talkback Program នៅក្នុងស្ថានីយវិទ្យុរបស់ខេត្ត។

កន្លងមក កម្មវិធី Talkback Program បានអញ្ជើញអភិបាលខេត្ត ក្រុង ស្រុក មេឃុំ ចៅសង្កាត់ និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីធ្វើបទសម្ភាសផ្ទាល់តាមវិទ្យុខេត្ត ក្នុងបំណងផ្តល់ព័ត៌មានជូនសាធារណៈជនឱ្យកាន់តែទូលំទូលាយ។ ប៉ុន្តែតាមការអនុវត្តជាក់ស្តែងនាពេលកន្លងមក កម្មវិធីនេះបានជួបនូវបញ្ហាប្រឈមខ្លះៗដូចជាការលំបាកក្នុងការសម្របសម្រួលជាមួយរដ្ឋបាលខេត្ត ក្នុងការជំរុញការអនុវត្តសកម្មភាពរបស់គម្រោង រួមទាំងមន្ត្រីថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានមន្ទីរជុំវិញខេត្ត និងមន្ត្រីពាក់ព័ន្ធមួយចំនួនមិនព្រមចូលរួមតាមការអញ្ជើញ។

ដោយយល់ឃើញពីសារៈសំខាន់នៃកម្មវិធីនេះ និងដោយកត់សម្គាល់នូវបញ្ហាប្រឈមនានាដូចបានរៀបរាប់ខាងលើ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដូចខាងក្រោម ៖

១). ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តគោលដៅ ត្រូវចូលរួមសម្របសម្រួល និងផ្តល់កិច្ចសហការឱ្យបានជាប់ជាប្រចាំជាមួយកម្មវិធី Talkback Program

២). អភិបាលខេត្តក្នុងនាមប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវណែនាំសម្របសម្រួល និងជំរុញឱ្យប្រធានមន្ទីរអង្គភាពនានាជុំវិញខេត្ត ចូលរួមក្នុងកម្មវិធី Talkback Program តាមការអញ្ជើញ។

៣). អភិបាលខេត្តត្រូវបញ្ជូនមន្ត្រីទទួលបន្ទុកព័ត៌មានខេត្ត ឱ្យចូលរួមផ្តល់ព័ត៌មានក្នុងកម្មវិធី Talkback Program ឱ្យបានទៀងទាត់តាមការអញ្ជើញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលខេត្តចាត់ចែងអនុវត្តតាមការគួរ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

សក់_សេដ្ឋា

ចម្លងជូន ៖
- ក្រសួងព័ត៌មាន
- វិទ្យុអេប៊ីស៊ីអូស្ត្រាលី
- ឯកសារ កាលប្បវត្តិ